ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
Ministry of Land Management, Urban Planning and Construction
លេខ(N₀): ១៨៩ ប្រក.ដនស/អសណ

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
Nation Religion King

# វិញ្ញាបនបត្របញ្ជាក់ការអនុញ្ញាតឲ្យប្រកបអាជីវកម្ម

## CERTIFICATE OF LICENSE

នាមករណ៍ ក្រុមហ៊ុន ប៊ែឡង់ស៍ អេនជីនារីង & ខនស្ត្រាក់សិន (ខេមបូឌា) ឯ.ក (សញ្ជាតិអង់គ្លេស) Name BALANCED ENGINEERING & CONSTRUCTION(CAMBODIA)CO., LTD.

លេខបញ្ជី ៥៩២ នសគប /១៧ សបរ កាលបរិច្ឆេទចុះបញ្ជី ០៣ សីហា ២០១៧ Registration Number : 592 NSKB / 17 SBR Registration Date : 03 August 2017

អាជីវកម្ម សាងសង់ ប្រភេទទី : ៣ Type of Business : Construction Class : 3

សុពលភាព : ពីថ្ងៃទី ០៩ ខែសីហា ឆ្នាំ ២០១៧ ដល់ថ្ងៃទី ០៩ ខែសីហា ឆ្នាំ ២០២០ Validity : 09 / August 2017 To 09 / August 2020

អ្នកកាន់វិញ្ញាបនបត្រនេះត្រូវគោរពច្បាប់ និងបទបញ្ញាជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

The Licensee shall observe and comply with Laws, Rules and Regulations of the Kingdom of Cambodia.

ថ្ងៃ ពុធ ២ រោច ខែ ស្រាពណ៍ ឆ្នាំ រកា ព.ស. ២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ សីហា គ.ស. ២០១៧
Phnom Penh, Date 09 August 2017

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
Senior Minister, Minister of Land Management, Urban Planning and Construction

ជា សុផារ៉ា

**ក្រុមហ៊ុនត្រូវផ្តល់របាយការណ៍ និងជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

- ក្រុមហ៊ុន ត្រូវផ្ញើរបាយការណ៍សកម្មភាពការងារប្រចាំឆ្នាំរបស់ខ្លួន មកក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់មុនដំណាច់ខែធ្នូនៃឆ្នាំនីមួយៗ។
- ក្នុងករណីមានការផ្លាស់ប្តូរទីស្នាក់ការក្រុមហ៊ុន និង/ឬផ្លាស់ប្តូរប្រធាន ឬនាយកបច្ចេកទេស ឬនាយកគម្រោង ក្រុមហ៊ុនត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ក្រុមហ៊ុនត្រូវទទួលម៉ៅការសាងសង់តែគម្រោងណាដែលមានលិខិតអនុញ្ញាតសាងសង់និងលិខិតអនុញ្ញាតបើកការដ្ឋាន**

- ការដ្ឋានពុំត្រូវចាប់ដំណើរការមុនពេលបានទទួលលិខិតអនុញ្ញាតសាងសង់ និងមុនពេលទទួលបានការអនុម័តលើប្លង់លម្អិតគ្រឿងផ្គុំសំណង់ឡើយ។ *(**មាត្រា ១៧** នៃអនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់)*
- ការដ្ឋាននីមួយៗអាចដំណើរការបាន លុះត្រាតែមានលិខិតអនុញ្ញាតបើកការដ្ឋាន។ *(**មាត្រា៣** នៃប្រកាសលេខ ៣២ ប្រក/សណ ចុះថ្ងៃទី ២០ ខែមីនា ឆ្នាំ ២០០១ ស្តីពីការគ្រប់គ្រងការដ្ឋានសំណង់)*

**ក្រុមហ៊ុនត្រូវដំណើរការការដ្ឋានតែក្នុងដរាបណាការដ្ឋាននោះមានធានារ៉ាប់រងលើភារៈទទួលខុសត្រូវការដ្ឋាន**

- ការធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋាន មានសារៈសំខាន់ក្នុងកិច្ចការពារផលប្រយោជន៍របស់តតិយជនទាំងឡាយ ដែលរស់នៅជុំវិញការដ្ឋាន ឬ ធ្វើដំណើរឆ្លងកាត់ ឬក្បែរការដ្ឋាន។ គ្រោះថ្នាក់ទាំងឡាយ ទោះបីដល់រូបរាងកាយក្តី ឬចំពោះទ្រព្យសម្បត្តិក្តី របស់តតិយជន ដែលបានបង្កឡើង ដោយសកម្មភាពរបស់ការដ្ឋាន សុទ្ធតែស្ថិតនៅក្នុងភារៈទទួលខុសត្រូវរបស់ម្ចាស់ការដ្ឋាន អ្នកម៉ៅការ ឬអ្នកម៉ៅការបន្ត។ *(**មាត្រា ៣៩** នៃអនុក្រឹត្យលេខ ១០៦ អនក្រ.បក ចុះថ្ងៃទី ២២ ខែតុលា ឆ្នាំ ២០០១ ស្តីពីធានារ៉ាប់រង)*
- ប្រភេទការដ្ឋានដែលចាំបាច់ត្រូវមានការធានារ៉ាប់រងលើភារៈទទួលខុសត្រូវ រួមមានការដ្ឋានសាងសង់ ជួសជុល តម្លើងទាំងអស់ ដែលទទួលខុសត្រូវដោយសហគ្រិន អ្នកម៉ៅការ ឬអ្នកម៉ៅការបន្ត....។ *(**មាត្រា ៤០** នៃអនុក្រឹត្យលេខ ១០៦ អនក្រ.បក ចុះថ្ងៃទី ២២ ខែតុលា ឆ្នាំ ២០០១ ស្តីពីធានារ៉ាប់រង)*
- ការធានារ៉ាប់រងលើភារៈទទួលខុសត្រូវការដ្ឋាន មានភារៈសំខាន់ក្នុងកិច្ចការពារផលប្រយោជន៍របស់តតិយជនទាំងឡាយដែលរស់នៅក្នុង ឬជុំវិញការដ្ឋាន ឬធ្វើដំណើរឆ្លងកាត់ ឬនៅក្បែរការដ្ឋាន។ *(**មាត្រា ១** នៃប្រកាសអន្តរក្រសួងលេខ ៦៥៥ ប្រក.សហវ.ដនស.មផ ចុះថ្ងៃទី ១៦ ខែតុលា ឆ្នាំ ២០០២ ស្តីពីកាតព្វកិច្ចធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋាន)*
- គ្រប់ការដ្ឋានសាងសង់ ជួសជុល តម្លើងទាំងអស់ ដែលទទួលខុសត្រូវដោយសហគ្រិន អ្នកម៉ៅការ ឬអ្នកម៉ៅការបន្ត ចាំបាច់ត្រូវមានការធានារ៉ាប់រងលើភារៈទទួលខុសត្រូវការដ្ឋាន។ *(**មាត្រា ២** នៃប្រកាសអន្តរក្រសួងលេខ ៦៥៥ ប្រក.សហវ.ដនស.មផ ចុះថ្ងៃទី ១៦ ខែតុលា ឆ្នាំ ២០០២ ស្តីពីកាតព្វកិច្ចធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋាន)*
- ការដ្ឋានសាងសង់នឹងមិនអាចមានដំណើរការបានទេ ដរាបណាការដ្ឋាននោះនៅមិនទាន់មានកាតព្វកិច្ចធានារ៉ាប់រងលើភារៈទទួលខុសត្រូវការដ្ឋាន។ *(**មាត្រា ៤** នៃប្រកាសអន្តរក្រសួងលេខ ៦៥៥ ប្រក.សហវ.ដនស.មផ ចុះថ្ងៃទី ១៦ ខែតុលា ឆ្នាំ ២០០២ ស្តីពីកាតព្វកិច្ចធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋាន)*